AFD

WWF

cirad
LA RECHERCHE AGRONOMIQUE
POUR LE DÉVELOPPEMENT



## សៀវភៅណែនាំពីបច្ចេកទេសសម្រាប់

# ការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រ

# Good Agricultural Practices (GAP) in Latex Harvesting

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមរដ្ឋមន្ត្រី នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូ ដែលបានផ្តួចផ្តើមចងក្រងសៀវភៅណែនាំបច្ចេកទេសនេះ។ ជាពិសេសសូមថ្លែងអំណរគុណដល់ទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍(AFD) និងមជ្ឈមណ្ឌលសហប្រតិបត្តិការស្រាវជ្រាវអន្តរជាតិ ដើម្បីអភិវឌ្ឍកសិកម្ម(CIRAD) ដែលបានផ្តល់ជាថវិកានិងប្រឹក្សាយោបល់បច្ចេកទេសក្នុងការរៀបចំចងក្រងសៀវភៅណែនាំបច្ចេកទេសនេះនិងអង្គការWWF-កម្ពុជាដែលបានផ្តល់ជាថវិកាសម្រាប់បោះពុម្ពសៀវភៅណែនាំនេះ។

រៀបចំដោយៈ នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ នៃអគ្គនាយកដ្ឋានកៅស៊ូ

គាំទ្រថវិការៀបចំដោយៈ ទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ (AFD)

គាំទ្រថវិកាបោះពុម្ពដោយៈ អង្គការWWF-កម្ពុជា

**ខែ កក្កដា ឆ្នាំ ២០២០**

បោះពុម្ពលើកទី១

៥០០ក្បាល

**អគ្គនាយកដ្ឋានកៅស៊ូ**

General Directorate of Rubber

National Road No.6A, Phum Bakkheng, Sangkat Prek Leap, Khan Chroy Chongva, Phnom Penh, Cambodia

Tel:(855) 23 67 22 590, 011 827 432

E-mail:gdr.maff@gmail.com

phengmuthavy@yahoo.com

# អារម្ភកថា

កៅស៊ូធម្មជាតិ គឺជាដំណាំយុទ្ធសាស្ត្រមួយប្រភេទដែលបានផ្តល់ប្រយោជន៍ជាច្រើនដល់សេដ្ឋកិច្ចជាតិ សង្គម និងបរិស្ថាន ជាពិសេសបានបង្កើនប្រាក់ចំណូលដល់គ្រួសារកសិករ បង្កើតការងារនិងមុខរបរ មានស្ថិរភាពនៅតាមតំបន់ជនបទ និងកាត់បន្ថយការធ្វើចំណាកស្រុក។ កៅស៊ូធម្មជាតិជាវត្ថុធាតុដើមសំខាន់សម្រាប់បម្រើវិស័យឧស្សាហកម្មផលិតជាមុខទំនិញរាប់ពាន់មុខ និងជាតម្រូវការប្រើប្រាស់ប្រចាំថ្ងៃដូចជា៖ សំបកកង់យានយន្ត សម្ភារក្នុងលំនៅដ្ឋាន ក្នុងផ្នែកវេជ្ជសាស្ត្រ ស្រោមដៃពេទ្យ ស្រោមអនាម័យ និងប្រើជាកំណល់សំណង់អគារ និងស្ពានធំៗ ទប់ទល់ការដួលរលំដោយសាររញ្ជួយផែនដី ចាក់ក្រាលផ្លូវថ្នល់ ផ្តល់ឈើកៅស៊ូប្រើប្រាស់សម្រាប់សំណង់ ផលិតគ្រឿងសង្ហារឹម ឈើឥន្ធនៈ។ ដំណាំកៅស៊ូក៏ចូលរួមចំណែកជួយកាត់បន្ថយការកាប់បំផ្លាញព្រៃឈើធម្មជាតិ ការពារការហូរច្រោះដី និងជាគម្របបៃតងឡើងវិញ ក្នុងការចូលរួមថែរក្សាលំនឹងបរិស្ថាន កាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដែលជាបញ្ហាប្រឈមរបស់ពិភពលោកក្នុងពេលបច្ចុប្បន្ននិងទៅអនាគត។

ការអនុវត្តកសិកម្មល្អលើការប្រមូលផលទឹកជ័រ គឺជាបង្គុំគោលការណ៍អនុវត្តបច្ចេកទេសល្អៗលើការយកផលទឹកជ័រនៅចម្ការកៅស៊ូ ដើម្បីបង្កើនប្រាក់ចំណូល តាមរយៈការទទួលបានទឹកជ័រច្រើនពីដើមកៅស៊ូ និងរក្សាបាននូវសុខភាពដើមកៅស៊ូ និងទាញយកផលយ៉ាងតិចបាន២៧ឆ្នាំ។ លើសពីនេះការអនុវត្តកសិកម្មល្អលើការប្រមូលផលទឹកជ័រ ក៏បានចូលរួមកាត់បន្ថយហានិភ័យដែលកើតមានឡើងពីការប្រែប្រួលអាកាសធាតុ ដែលនាំឲ្យមានការបាត់បង់ផលិតភាពកៅស៊ូនៅចម្ការ ដែលភាគច្រើនកើតឡើងដោយសារហេតុការណ៍មួយចំនួនដូចជាប្រែប្រួលរបបទឹកភ្លៀង (មានកម្រិតខ្ពស់ និងកម្រិតទាបខ្លាំង) សីតុណ្ហភាពខ្ពស់

ក្នុងរដូវប្រាំង និងការអូសបន្លាយរដូវប្រាំងជាដើម។ ការបង្កើតការអនុវត្តកសិកម្មល្អលើការប្រមូលផលទឹកជ័រ ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យនិងស្តង់ដានៃការបើកមុខចៀរ ការត្រួតពិនិត្យលើគុណភាពនៃការចៀរជ័រ ប្រព័ន្ធចៀរជ័រ ការធ្វើរំញោចកម្មការផ្អាកការចៀរជ័រ និងការប្រើប្រាស់ជីនៅពេលកៅស៊ូផ្តល់ផលផងដែរ។

សៀវភៅណែនាំបច្ចេកទេសនេះ ត្រូវបានរៀបចំឡើងដើម្បីកាត់បន្ថយនិងដោះស្រាយបញ្ហាប្រឈមរបស់អ្នកដាំកៅស៊ូជាពិសេសកសិករកៅស៊ូគ្រួសារ ទៅនឹងការបម្រែបម្រួលអាកាសធាតុ ដើម្បីធានាការអភិវឌ្ឍកៅស៊ូប្រកបដោយនិរន្តរភាព។ ម្យ៉ាងទៀត សៀវភៅនេះក៏បានចូលរួមចំណែកជាចំណេះដឹងថ្មីៗបន្ថែមដល់មន្ត្រីការិយាល័យកៅស៊ូតាមបណ្តាខេត្ត និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ដើម្បីបញ្ជ្រាបដល់អ្នកដាំដុះកៅស៊ូនៅតាមមូលដ្ឋាន។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមរដ្ឋមន្ត្រី នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូ ដែលបានផ្តួចផ្តើមចងក្រងសៀវភៅណែនាំបច្ចេកទេសនេះ។ ជាពិសេសសូមថ្លែងអំណរគុណដល់ទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ (AFD) និងមជ្ឈមណ្ឌលសហប្រតិបត្តិការស្រាវជ្រាវអន្តរជាតិ ដើម្បីអភិវឌ្ឍកសិកម្ម (CIRAD) ដែលបានផ្តល់ជាថវិកានិងប្រឹក្សាយោបល់បច្ចេកទេស ក្នុងការរៀបចំចងក្រងសៀវភៅណែនាំបច្ចេកទេសនេះ និងអង្គការ WWF-កម្ពុជា ដែលបានផ្តល់ជាថវិកាសម្រាប់បោះពុម្ពសៀវភៅណែនាំនេះ។

អគ្គនាយកដ្ឋានកៅស៊ូ សូមស្វាគមន៍ទទួលយកនូវរាល់យោបល់កែលម្អបន្ថែមទៀតពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធ ដើម្បីបោះពុម្ពលើកក្រោយឲ្យបានល្អប្រសើរ។

**អគ្គនាយកដ្ឋានកៅស៊ូ!**

# មាតិកា


**១ - បទដ្ឋាននៃការបើកមុខចៀរដំបូង ---------- ១**

១.១ - ទំហំដើម និងអាយុកាលនៃដើម ---------- ២

១.១.១- ករណីទូទៅ (កំណើនលូតលាស់ដើមធម្មតា) ---------- ២

១.១.២- ការផ្លាស់ប្តូរបទដ្ឋាននៃការបើកមុខចៀរដំបូង ---------- ៤

១.២ - កម្ពស់មុខចៀរ ---------- ៥

១.៣ - ចំណោតមុខចៀរ ---------- ៦

១.៤ - ទីតាំងផ្ទាំងចៀរពេលបើកមុខចៀរ ---------- ៦

១.៥ - ការចៀរលើដើមបំពេញបន្ថែម ---------- ៧

**២ - គុណភាពចៀរជ័រ ---------- ៨**

២.១ - ការចំណាយសំបក ---------- ៨

២.២ - ជម្រៅចៀរ ---------- ១១

**៣ - ប្រព័ន្ធចៀរ ---------- ៨**

៣.១ - ចង្វាក់ចៀរ ---------- ១៣

៣.១.១- ការចៀរធម្មតា ---------- ១៣

៣.១.២- ការចៀរសម្លាប់ដើម ---------- ១៣

៣.២ - លំដាប់លំដោយនៃការគ្រប់គ្រងផ្ទាំងចៀរ ---------- ១៤

៣.៣ - ការធ្វើរំញោចកម្ម ដោយថ្នាំអេតេហ្វូន ---------- ១៧

៣.៣.១- វិធីសាស្រ្តនៃការធ្វើរំញោចកម្ម ---------- ១៧

៣.៣.២- ប៉ារ៉ាម៉ែត្រនៃការធ្វើរំញោចកម្ម ---------- ១៩

**៤ - ការគ្រប់គ្រងពេលផ្អាកចៀរនៅអំឡុងពេលរដូវជ្រុះស្លឹក ---------- ២៨**

៥ - ការបញ្ចៀសទឹកភ្លៀង ---------------------------------------------------៣១
៦ - ការដាក់ជីលើដើមកៅស៊ូពេញវ័យ ---------------------------------៣១

# រូបភាព


រូបភាពទី១ ៖ ផ្ទាំងចៀរ និងចានត្រងជ័រ នៅស្របជាមួយរងកៅស៊ូ -------------- ៧
រូបភាពទី២ ៖ ការវាស់លើការចំណាយសំបក និងក្រិតប្រចាំខែ (S/2 d3)----- ១០
រូបភាពទី៣ ៖ ការវាស់លើការចំណាយសំបក និងក្រិតប្រចាំខែ (S/4 U d3) - ១១
រូបភាពទី៤ ៖ ការចៀររាក់(ដោយគ្មានរបួសនៅលើផ្ទាំងចៀរគួរតែពិនិត្យជាប្រព័ន្ធទៅលើជម្រៅចៀរ) ------------------------------------------------ ១១
រូបភាពទី៥ ៖ ការខូចខាតសំបកដែលមិនអាចកែប្រែបាន ដោយសារតែរបួស (ចៀរដល់សាច់ឈើ) ------------------------------------------------------ ១២
រូបភាពទី៦ ៖ លំដាប់លំដោយនៃការគ្រប់គ្រងផ្ទាំងចៀរសម្រាប់អនុសាសន៍ចង្វាក់ចៀរ d3 និង d4 ---------------------------------------------------- ១៦
រូបភាពទី៧ ៖ ការអនុវត្តរំញោចកម្មលើផ្ទាំងចៀរ -------------------------------- ១៨
រូបភាពទី៨ ៖ ការលាបថ្នាំរំញោចលើការចៀរមុខក្រោម ------------------------ ១៨
រូបភាពទី៩ ៖ ការលាបថ្នាំរំញោចលើការចៀរមុខលើ --------------------------- ១៩
រូបភាពទី១០៖ដំណាក់កាលនៃការវិវត្តរបស់ស្លឹកកៅស៊ូដុះឡើងវិញ ------------ ២៩

# តារាង

តារាងទី១ ៖ ចំណាត់ថ្នាក់ក្លូនតាមសកម្មភាពមេតាបូលីសសម្រាប់ផ្តល់អនុសាសន៍ដល់ការចៀរជ័រ(ចង្វាក់ចៀរនិងការធ្វើរំញោចកម្ម) ---------------- ២៣
តារាងទី២ ៖ អនុសាសន៍សម្រាប់ប្រព័ន្ធចៀរ S/2 d3 (N) : 2,5% អេតេហ្វូន Ethephon (2,5% Et) ---------------------------------------------------------- ២៥
តារាងទី៣ ៖ អនុសាសន៍សម្រាប់ប្រព័ន្ធចៀរ S/4 d3 (UTS) : អេតេហ្វូន Ethephon (5% Et) ------------------------------------------------------------- ២៦
តារាងទី៤ ៖ អនុសាសន៍សម្រាប់ប្រព័ន្ធចៀរ S/2 d4 (N) : 2,5% អេតេហ្វូន Ethephon (2,5% Et) ---------------------------------------------------------- ២៧
តារាងទី៥ ៖ អនុសាសន៍សម្រាប់ប្រព័ន្ធចៀរ S/4 d4 (UTS) : អេតេហ្វូន Ethephon (5% Et) ------------------------------------------------------------- ២៨

# ការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រ

សៀវភៅណែនាំបច្ចេកទេសនេះ ផ្តោតទៅលើការយកផលទឹកជ័រប៉ុណ្ណោះ ក្នុងការធ្វើឲ្យល្អប្រសើរប្រព័ន្ធចៀរជ័រ សម្រាប់ដំណាក់កាលកៅស៊ូពេញវ័យ (Mature Period)។ បច្ចេកទេសការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រគួរអនុវត្តដូចខាងក្រោម៖

## ១- បទដ្ឋាននៃការបើកមុខចៀរដំបូង

បទដ្ឋាននៃការបើកមុខចៀរដំបូងត្រូវបានកំណត់យ៉ាងត្រឹមត្រូវ យោងតាមលក្ខណៈវិនិច្ឆ័យចំនួនប្រាំ៖

- ទំហំដើម និងអាយុកាលនៃដើម (លក្ខណៈវិនិច្ឆ័យទាំង២នេះត្រូវបានផ្សំបញ្ចូលគ្នាព្រោះវាមានសារៈសំខាន់ណាស់ដើម្បីសម្រេចបានផលិតផលជាអតិបរមានិងនិរន្តរភាព)
- កម្ពស់បើកមុខចៀរ (អាស្រ័យលើចង្វាក់ចៀរ)
- ចំណោតមុខចៀរ
- ទីតាំងផ្ទាំងចៀរលើដើម (ដើម្បីបង្កើនប្រសិទ្ធភាពចៀរ និងកាត់បន្ថយពេលវេលាដើររបស់អ្នកចៀរ)
- លក្ខខណ្ឌនៃការបើកមុខចៀរបន្ថែមលើដើមដែលមិនទាន់បានបើកមុខ (ដើម្បីសម្រេចឲ្យបានឆាប់តាមដែលអាចធ្វើទៅបាននូវចំនួនដើមចៀរជាអតិបរមា)។

## ១.១- ទំហំដើម និងអាយុកាលនៃដើម

### ១.១.១. ករណីទូទៅ (កំណើនលូតលាស់ដើមធម្មតា)

ការឆាប់បើកមុខចៀរ (អាយុតិចជាង៥ឆ្នាំ ឬទំហំរង្វង់ដើមតូចជាង ៤៥ ស.ម. វាស់នៅកម្ពស់១ម៉ែត្រពីដី) នាំឲ្យមានការបាត់បង់ផលិតផលដែលមិនអាចទាញយកមកវិញបាន។ ជាទូទៅ ការលូតលាស់នៃទំហំដើម មុនពេលចាប់ផ្តើមចៀរ គឺមានចាប់ពី៦ស.ម. ទៅ១០ស.ម. ក្នុងមួយឆ្នាំ និងក្រោយពីការចាប់ផ្តើមចៀរជ័រ ការលូតលាស់នៃទំហំដើមមានចាប់ពី១ស.ម.ទៅ២ស.ម.ក្នុងមួយឆ្នាំតែប៉ុណ្ណោះ។ នេះគឺដោយសារតែការប្រើប្រាស់កាបូអ៊ីដ្រាត(carbohydrates) និងថាមពលមេតាប៉ូលីស(metabolic energy)សម្រាប់បង្កើតឡើងវិញនូវទឹកជ័រនៅពេលដែលចាប់ផ្តើមចៀរជ័រ ដែលវាប្រកួតប្រជែងជាមួយការលូតលាស់នៃដើម។ ជាផលវិបាក ការបើកមុខចៀរលើដើមតូចធ្វើឲ្យដើមលូតលាស់យឺត និងទទួលបានទិន្នផលទាបក្នុង១វដ្តនៃចម្ការកៅស៊ូទាំងមូល។

លើសពីនេះទៀត ការឆាប់បើកមុខចៀរ (អាយុតិចជាង៥ឆ្នាំ) មិនត្រូវបានណែនាំឡើយ ពីព្រោះដើមកៅស៊ូត្រឹមអាយុ៤ឆ្នាំ ការធ្វើមេតាបូលីសទាំងមូលគឺមានអាទិភាពចំពោះតែការលូតលាស់ដើមប៉ុណ្ណោះ(ដំណើរការបង្កើតជីវម៉ាស់) ហើយដើមកៅស៊ូមិនអាចរក្សាទុកកាបូអ៊ីដ្រាតបម្រុងបានទេ។ ហេតុដូច្នេះ ការឆាប់បើកមុខចៀរ(អាយុតិចជាង៥ឆ្នាំ)នឹងបង្កគ្រោះថ្នាក់ដល់និរន្តរភាពនៃទិន្នផលជ័រនៅពេលដែលដើមកៅស៊ូមានអាងបម្រុងកាបូអ៊ីដ្រាតទាប (low carbohydrate reserve pool)។ ការថយចុះនៃអាងបម្រុងជាតិស្ករ នាំឲ្យការផ្គត់ផ្គង់ជាតិស្ករសម្រាប់ផលិតទឹកជ័រថយចុះការលូតលាស់នៃដើមថយចុះនៅពេលចៀរ ដែលនាំឲ្យការបាក់ដើមដោយសារខ្យល់បក់ខ្លាំង កាត់បន្ថយការឆ្លើយតបទៅនឹងការធ្វើរំញោចកម្ម និងមានការកើនឡើងនៃការស្ងួតផ្ទាំងចៀរ។

**ជាអនុសាសន៍ទូទៅ ដើម្បីចាប់ផ្តើមបើកមុខចៀរដំបូងបាន គឺនៅពេលដើមកៅស៊ូមានទំហំដើមអប្បបរមា ៥០ស.ម. វាស់កម្ពស់១ម៉ែត្រពីដី (ឬ ៤៥ស.ម. វាស់កម្ពស់១,៥ម.ពីដី) ចាប់ពីចំនួន៥០% នៃឡូត៍ដែលត្រូវចៀរ ដែលមានអាយុអប្បបរមា ៥ឆ្នាំយ៉ាងតិច។**

ដើមកៅស៊ូដែលអាចបើកមុខចៀរដំបូងបាន ត្រូវមានទំហំដើមអប្បបរមា ៥០ស.ម. វាស់នៅកម្ពស់១ម៉ែត្រពីដីត្រូវបានគេចាត់ទុកថាជាទំហំដើមដ៏ប្រសើរបំផុត ជាមួយនឹងឆ្នាំដាំអប្បបរមា៥ឆ្នាំយ៉ាងតិច ដែលអាចផ្តល់ផលិតផលគ្រប់គ្រាន់នៅពេលបើកមុខចៀរដំបូង។ វាគឺជាលក្ខណៈវិនិច្ឆ័យជីវសាស្រ្ត ដើម្បីសម្រេចថាតើដើមណាអាចចៀរបាន និងដើមណាមិនអាចចៀរបាន។ ចំនួន៥០% នៃដើមអាចចៀរបាន គឺជាការកំណត់ពេលដ៏ល្អបំផុតសម្រាប់ឡូត៍បើកមុខចៀរដំបូង។ វាគឺជាលក្ខណៈវិនិច្ឆ័យសេដ្ឋកិច្ចដើម្បីសម្រេចថាតើឡូត៍នោះអាចចៀរបានឬក៏អត់។

ការបើកមុខចៀរដំបូងត្រូវបានផ្តល់អនុសាសន៍ ឲ្យបើកតែនៅក្នុងបណ្តាខែបន្ទាប់ពីចម្ការកៅស៊ូដុះស្លឹកពេញលេញឡើងវិញ (ខែមេសា ឧសភា មិថុនា កក្កដា និងសីហា)។ ប្រសិនបើឡូត៍កៅស៊ូមិនអាចបើកមុខចៀរបាននៅចុងខែសីហានោះទេ ត្រូវពន្យារពេលដល់ឆ្នាំបន្ទាប់ដើម្បីទទួលបានទំហំដើមធំល្អនៅពេលបើកមុខចៀរ។ ជាការពិត ការបើកមុខចៀរនៅខែកញ្ញា ឬក៏ខែបន្ទាប់មកទៀតនឹងទទួលបានទិន្នផលទាប គឺចាប់ពីខែកញ្ញាដល់ខែមីនា (ផលិតផលកើនចាប់ពីខែកញ្ញាដល់ខែវិច្ឆិកា និងផលិតផលថយចុះចាប់ពីខែធ្នូ ដោយសារការចាប់ផ្តើមនៃរដូវជ្រុះស្លឹក) និងបានណែនាំឲ្យពន្យាពេលបើកមុខចៀររហូតដល់ខែមេសាឆ្នាំក្រោយ (ចំនួនដើមដែលត្រូវបើកមុខចៀរមានចំនួនច្រើន និងមានទំហំធំ)។

ករណីការបើកមុខចៀរដំបូងចាប់ផ្តើមនៅខែមេសា ឧសភា មិថុនា កក្កដា ឬសីហា ឆ្នាំនៃផលិតផលត្រូវបានគេរាប់ថាជាការចៀរឆ្នាំទី១។ ក្នុងករណីដែលការបើកមុខចៀរមានការយឺត គឺនៅក្នុងខែកញ្ញាឬខែបន្ទាប់ ឆ្នាំនៃផលិតផលត្រូវបានគេ

រាប់ថាជាការចៀរឆ្នាំទី« ០ »មិនមែនជាឆ្នាំទី១ទេ។ ក្នុងករណីនេះ ការចៀរលើសំបកកំណើតផ្ទាំងចៀរBO-1(A) មានរយៈពេលលើសពី៦ឆ្នាំ មុនពេលប្ដូរទៅចៀរលើសំបកកំណើតផ្ទាំងចៀរBO-2(B) និងដែលអាចក្លាយជាបញ្ហាបន្ថែមទៀតក្នុងករណីដែលមានការចំណាយសំបកលើសការកំណត់។

### ១.១.២-ការផ្លាស់ប្ដូរបទដ្ឋាននៃការបើកមុខចៀរដំបូងចំពោះតំបន់ដែលមានសក្ដានុពលដីដាំដុះទាប

បទដ្ឋាននៃការបើកមុខចៀរដំបូងល្អបំផុត គឺធានាបានទាំងស្រុងនូវនិរន្តរភាពជាអតិបរមាក្នុងតំបន់ដីដែលកៅស៊ូដុះលូតលាស់ធម្មតា ឬល្អប្រសើរ ត្រូវធ្វើការបើកមុខចៀរនៅឆ្នាំទី៥ ទី៦ ឬទី៧។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលដើមកៅស៊ូដាំនៅតំបន់ដីងាយរងគ្រោះ (តំបន់ទំនាបដែលងាយរងនឹងទឹកលិច តំបន់ដីស្រទាប់រឹង តំបន់អាកាសធាតុស្ងួត ឬត្រជាក់) ឬក្នុងករណីចម្ការមិនមានការថែទាំដែលលក្ខណៈទាំងអស់នេះធ្វើឲ្យកៅស៊ូដុះលូតលាស់មិនបានល្អ ឬក៏ត្រូវពន្យាពេលបើកមុខចៀរដែលភាគច្រើនអ្នកដាំដុះកៅស៊ូមិនអាចទទួលយកបាន។ ក្នុងករណីនេះ លក្ខណៈវិនិច្ឆ័យនៃការបើកមុខចៀរដំបូងត្រូវប្រែប្រួល បើមិនដូច្នេះទេនឹងនាំឲ្យមានការកាត់បន្ថយចំនួនដើមចៀរជាបន្ថែមទៀត។ ប្រសិនបើលក្ខណៈវិនិច្ឆ័យសេដ្ឋកិច្ច (៥០% នៃដើមក្នុងឡូត៍ដែលមានទំហំដើមអប្បបរមា៥០ស.ម. វាស់នៅកម្ពស់១ម៉ែត្រពីដី ឬ៤៥ស.ម. វាស់នៅកម្ពស់១,៥ម៉ែត្រពីដី)មានរយៈពេលលើសពី៧ឆ្នាំនោះ បទដ្ឋាននៃការបើកមុខចៀរដំបូងត្រូវបានកែសម្រួលទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

ប្រសិនបើក្រោយរយៈពេល៧ឆ្នាំបន្ទាប់ពីការដាំដុះ បង្ហាញពីការលូតលាស់នៃដើមមានភាពយឺត ធៀបទៅនឹងលក្ខខណ្ឌធម្មតានោះ ការបើកមុខចៀរដំបូងលើដើមកៅស៊ូទាំងអស់ដែលមានទំហំដើមចាប់ពី៤៥ស.ម. (ឬក៏៤០ស.ម. ក្នុងករណី

ដែលដើមកៅស៊ូមានការលូតលាស់ខ្សោយ) វាស់នៅកម្ពស់១ម៉ែត្រពីដី គួរតែអនុវត្ត នៅឆ្នាំទី៨។ ក្នុងករណីណាក៏ដោយ ការបើកមុខចៀរដំបូងមិនគួរពន្យាពេលក្រោយ ឆ្នាំទី៨ទេ ព្រោះវានឹងមិនមានភាពប្រសើរឡើយចំពោះស្ថានភាពដូច្នេះ ឬក៏បណ្តាល ឲ្យមានភាពយឺតយ៉ាវ។

### ១.២- កម្ពស់មុខចៀរ

កម្ពស់មុខចៀរត្រូវបានកំណត់ទៅតាមចង្វាក់ចៀរ។ ដូច្នេះវាជាការចាំបាច់ណាស់ ដើម្បីឲ្យដឹងថាតើចង្វាក់ចៀរមួយណាដែលត្រូវយកមកអនុវត្តមុនពេលចាប់ផ្តើមបើកមុខចៀរ។ កម្ពស់មុខចៀរត្រូវបានកំណត់ដើម្បីរក្សាការអនុវត្តចៀរលើផ្ទាំងចៀរ BO-1(A)យ៉ាងហោចណាស់ឲ្យបាន៦ឆ្នាំ មុនពេលប្តូរទៅផ្ទាំងចៀរ BO-2 (B) ដោយគិតថាបទដ្ឋាននៃការចំណាយសំបកក្នុងមួយពន្លាកគឺអនុវត្តត្រឹមត្រូវ។

ចង្វាក់ចៀរនីមួយៗត្រូវបានកំណត់ដូចខាងក្រោម៖

- S/2 d2 6d/7 ឬ 7d/7: ផ្ទាំងចៀរ BO-1 វាស់នៅកម្ពស់ 1,50 m ពីដី
- S/2 d3 6d/7 ឬ 7d/7: ផ្ទាំងចៀរ BO-1 វាស់នៅកម្ពស់ 1,30 m ពីដី
- S/2 d4 6d/7 ឬ 7d/7: ផ្ទាំងចៀរ BO-1 វាស់នៅកម្ពស់ 1,20 m ពីដី
- S/2 d5 6d/7 ឬ 7d/7: ផ្ទាំងចៀរ BO-1 វាស់នៅកម្ពស់ 1,20 m ពីដី
- S/2 d6 6d/7 ឬ 7d/7: ផ្ទាំងចៀរ BO-1 វាស់នៅកម្ពស់ 1,10 m ពីដី

### ១.៣- ចំណោតមុខចៀរ

ចំណោតមុខចៀរមុំ៣៥ដឺក្រេ ត្រូវបានផ្តល់អនុសាសន៍ចំពោះការចៀរចុះក្រោម។ ជាទូទៅ ត្រូវជៀសវាងការកែចំណោតមុខចៀរក្នុងអំឡុងពេលចៀរ៦ឆ្នាំដំបូង ទោះបីជាដើមកៅស៊ូលូតលាស់ធំក៏ដោយ ក៏ចំណោតមុខចៀរលើផ្ទាំងចៀរ BO-1(A) នៅរក្សាចំណោតមុំគ្រប់ពេល ដែលជាធម្មតាគឺនៅចន្លោះមុំពី៣០ដឺក្រេ ទៅ៣៥ដឺក្រេ។

ចំណោតមុខចៀរទាប ឬខ្ពស់ ជានិច្ចជាកាលនាំឲ្យបាត់បង់ផលិតផល។ ប្រសិនបើចំណោតមុខចៀរទាបជាង៣០ដឺក្រេ វានឹងកាត់បន្ថយចំនួនសរសៃទឹកជ័រនៅពេលចៀរ កាត់បន្ថយប្រសិទ្ធភាពនៃលំហូរទឹកជ័រដែលនាំឲ្យទឹកជ័រកកនៅលើមុខចៀរ និងបង្កើនការហៀរទឹកជ័រលើដើម។ ប្រសិនបើចំណោតមុខចៀរខ្ពស់ជាង៣៥ដឺក្រេ ការខាតបង់ទឹកជ័រនឹងកើនឡើងដោយសារភ្លៀង និងបង្កើនការហៀរទឹកជ័រនៅលើដើមនៅពេលអាកាសធាតុសើម។

### ១.៨- ទីតាំងផ្ទាំងចៀរពេលបើកមុខចៀរ

នៅក្នុងការអនុវត្តចៀរជ័រ តាមរបៀបធម្មតា និងសម័យទំនើប ផ្ទាំងចៀរគួរតែស្របទៅនឹងរងកៅស៊ូដើម្បីកាត់បន្ថយការដើររបស់អ្នកចៀរ (ជាពិសេសចៀសវាងអ្នកចៀរដើរជុំវិញដើមមុនពេលទៅដល់ទីតាំងចាប់ផ្តើមចៀរនៃដើមបន្ទាប់)។ ប្រសិនបើផ្ទាំងចៀរកែងទៅនឹងរងកៅស៊ូ អ្នកចៀរនឹងចំណាយពេលដើរជុំវិញដើមមុននឹងចាប់ផ្តើមចៀរនៅដើមបន្ទាប់ ដែលជាហេតុបណ្តាលឲ្យអ្នកចៀរចំណាយពេលវេលាច្រើនក្នុងការដើរ និងពន្យាពេលវេលាចៀរ ធ្វើឲ្យការហូរនៃទឹកជ័រមានរយៈពេលខ្លី និងប៉ះពាល់ដល់ផលិតផលកៅស៊ូ។

ម្យ៉ាងវិញទៀត នៅពេលដែលផ្ទាំងចៀរទាំងអស់នៅស្របទៅនឹងរងកៅស៊ូ គេអាចមើលឃើញផ្ទាំងចៀរទាំងមូលពីចន្លោះរងកៅស៊ូ ដែលធ្វើឲ្យម្ចាស់ចម្ការ និងអ្នកជំនួយការ ងាយស្រួលក្នុងការពិនិត្យទៅលើការចៀរ ការធ្វើរំញោចកម្ម និងការត្រួតពិនិត្យលើគុណភាពនៃការចៀរជ័រផងដែរ។ ផ្ទាំងចៀរនិងទិសនៃការចៀរ ត្រូវបានបង្ហាញលើរូបភាពទី១។

### ១.៩- ការចៀរលើដើមកៅស៊ូបំពេញបន្ថែម

ការចៀរជ័រលើដើមកៅស៊ូបំពេញបន្ថែមនៅឆ្នាំទី២ និងឆ្នាំទី៣ គឺអនុវត្តដូចគ្នាទៅនឹងលក្ខណៈវិនិច្ឆ័យនៃការបើកមុខចៀរដំបូង។ នៅដើមឆ្នាំទី៤បន្ទាប់ពីបើក

មុខចៀរដំបូង ត្រូវបានគេណែនាំឲ្យបើកមុខចៀរដើមកៅស៊ូបំពេញបន្ថែមទាំងអស់ ដែលមិនទាន់បានចៀរចាប់ពីទំហំអប្បបរមា៤០ស.ម.ឡើងទៅ វាស់នៅកម្ពស់មួយម៉ែត្រពីដី។ ចំពោះគ្រប់ដើមកៅស៊ូទាំងអស់ដែលមិនបានចៀរ នៅក្រោមទំហំ៤០ ស.ម. ត្រូវបានគេចាត់ទុកថា ជាដើមមិនអាចចៀរបាន ដោយសារសក្ដានុពលទិន្នផលទាបខ្លាំង។

ក្នុងគ្រប់ករណីទាំងអស់ ការចៀរលើដើមបំពេញបន្ថែម គឺអនុវត្តតែនៅលើផ្ទាំងចៀរ BO-1(A) នៅកម្ពស់កម្រិតចម្ការ (កំពស់ជាមធ្យមនៃកម្ពស់មុខចៀរដំបូង) ដើម្បីឲ្យគ្រប់មុខចៀរ ចានត្រងជ័រ និងផ្ទាំងចៀរនៅកម្ពស់ស្មើគ្នាគ្រប់ពេល ក្នុងប្លុកតែមួយ(រូបភាពទី១)។



*រូបភាពទី១៖ ផ្ទាំងចៀរ និងចានត្រងជ័រ នៅស្របជាមួយរងកៅស៊ូ*

## ២- គុណភាពចៀរជ័រ (Tapping quality)

ផលិតផលកៅស៊ូពឹងផ្អែកទៅនឹងសក្ដានុពលទិន្នផលរបស់ក្លូន(ពូជដំណាំ) ជីជាតិដី និងអាកាសធាតុ ដូចជាដំណាំដទៃទៀតដែរ ប៉ុន្តែអ្វីដែលពិសេសជាងនេះ

គឺជំនាញរបស់អ្នកចៀរជ័រនៅពេលចៀរ។ ជាការពិត បើយើងមិនចៀរនឹងមិនបានទិន្នផលទេ ហើយភាពត្រឹមត្រូវនៃការចៀរជ័រ (គុណភាពចៀរជ័រ) រួមនឹងការអនុវត្តចៀរ (បច្ចេកវិទ្យាប្រមូលផលទឹកជ័រ) គឺជាអ្នកកំណត់ទាំងស្រុងលើទិន្នផលជាក់ស្តែងដែលអាចសម្រេចបាន។ គុណភាពចៀរជ័រមិនត្រឹមត្រូវអាចធ្វើឲ្យអន្តរាយទាំងស្រុងសូម្បីតែសក្តានុពលទិន្នផលលើចម្ការកៅស៊ូពេញវ័យទាំងមូលក៏ត្រូវបានបំផ្លាញ។

ប៉ារ៉ាម៉ែត្រពីរសំខាន់នៃគុណភាពចៀរជ័រគឺការចំណាយសំបក និងជម្រៅចៀរ។ ចំណុចទាំងពីរនេះត្រូវតែធានាឲ្យបាននៅក្នុងស្តង់ដាកម្រិតល្អបំផុតដែលអាចធ្វើទៅបាន ដើម្បីធានាថាដំណាំដែលមានសក្តានុពលនឹងទទួលបាននូវផលិតផលខ្ពស់ពិតប្រាកដ។

ហេតុដូច្នេះ អ្នកចៀរជ័រត្រូវមានជំនាញ មានន័យថាមានកន្លែងបណ្តុះបណ្តាល(សាលាបង្រៀនចៀរជ័រ) ដែលអ្នកចៀរអាចទទួលបាននូវជំនាញ និងទទួលបានការបណ្តុះបណ្តាលពីការអនុវត្តចៀរជ័រត្រឹមត្រូវ។ នៅកម្ពុជា អគ្គនាយកដ្ឋានកៅស៊ូ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាអ្នករៀបចំការបណ្តុះបណ្តាលជំនាញចៀរជ័រនៅតាមមូលដ្ឋាន។

### ២.១- ការចំណាយសំបក (Bark consumption)

ការចំណាយសំបកស្តើង ឬលើសពីបទដ្ឋានកំណត់ក្នុងអំឡុងពេលចៀរជ័រជានិច្ចជាកាលនាំឲ្យខាតបង់ផលិតផលជ័រ។ ការចំណាយសំបកតិចពេក ត្រូវតែជៀសវាងតាមតែអាចធ្វើទៅបាន ក្នុងគោលបំណងចៀរឲ្យដល់កម្រាស់សំបកដែលមានជាលិការស់។ ការចៀរយកកម្រាស់សំបកស្តើងពេក កើតមានឡើងតែនៅលើសំបកជាលិកាខូច ដែលផ្ទៃមុខចៀរនេះបានស្ងួតនៅចន្លោះ២ពន្លាក (ដោយដំណើរការជាសះស្បើយ ឥទ្ធិពលព្រះអាទិត្យ ខ្យល់ ការបំផ្លាញដោយផ្សិត និងបាក់តេរី)។ ទោះជាយ៉ាងណាក៏ដោយ ការបាត់បង់ផលិតផលដោយសារការចំណាយសំបក

ស្តើង នៅតែមានកម្រិតទាបជាងការចំណាយសំបកលើសការកំណត់។ លើសពីនេះទៀត ការចំណាយសំបកស្តើង គឺគេកម្រអនុវត្តបានណាស់ ហើយសារៈសំខាន់នៃសេដ្ឋកិច្ចគឺមានកម្រិតតិចតួចបំផុត។

ការចំណាយសំបកលើសកំណត់ ជាមូលហេតុចម្បងនៃការបាត់បង់ផលិតផល ដោយសារតែការអនុវត្តចៀរជ័រមិនបានល្អ។ ការចំណាយសំបកលើសនេះគឺបាត់បង់ផលិតផលស្មើនឹង២០% នៃផលិតផលសរុបក្នុង១វដ្តនៃដើមកៅស៊ូ។ មូលហេតុទី១ គឺដោយសារការបាត់បង់សំបកដែលជាការបាត់បង់ផ្នែកសេដ្ឋកិច្ចផ្ទាល់(ការបាត់បង់ទុន)ដែលមិនអាចផ្តល់ទិន្នផលវិញបាន។ មូលហេតុទី២ ដោយសារតែការធ្វើអន្តរកម្ម(Interacting)ជាមួយជាតិស្ករបម្រុង (starch) ក្នុងដើម។ ឧទាហរណ៍ ការចំណាយសំបកលើសលើផ្ទាំងចៀរBO-1(A) សម្រាប់រយៈពេល៦ឆ្នាំដំបូង នៃការទាញយកផលនឹងនាំឲ្យមានការឆាប់ផ្លាស់ប្តូរទៅផ្ទាំងចៀរBO-2(B) និងបន្ទាប់មកលើផ្ទាំងចៀរមុខលើ ហើយផ្ទាំងចៀរទាំងអស់នោះនឹងចុះខ្សោយជាងធម្មតា ដោយសារការរក្សាទុកជាតិស្ករបម្រុងមានរយៈពេលខ្លី បើធៀបនឹងពេលវេលាធម្មតា។ ការចំណាយសំបកលើសកំណត់ក្នុងការចៀរមុខលើ នឹងនាំមកនូវការឆាប់ប្រើប្រាស់ជាតិស្ករបម្រុងដែលមានកម្រិតខ្ពស់ និងការឆាប់កើតឡើងនៃចំណិតសំបកសល់ពីការចៀរ (Island barks) ដែលនាំឲ្យរារាំងដល់ការផ្គត់ផ្គង់ជាតិស្ករ និងដែលជាលទ្ធផលនាំឲ្យមានការបាត់បង់ផលិតផលកៅស៊ូយ៉ាងច្រើនផងដែរ។

បទដ្ឋានអន្តរជាតិនៃការចៀរមុខក្រោម (S/2 )សម្រាប់ចង្វាក់ចៀរd3 និងd4៖

- S/2 d3: ចំណាយសំបកក្នុង១ឆ្នាំ15cm-18cm ដែលល្អបំផុតគឺ15cm(កម្រាស់សំបកក្នុង១ពន្លាក1,3mm-1,5mm)
- S/2 d4: ចំណាយសំបកក្នុង១ឆ្នាំ12cm-15 cm ដែលល្អបំផុតគឺ 12cm(កម្រាស់សំបកក្នុង១ពន្លាក1,5mm-1,8mm)



*រូបភាពទី២៖ ការវាស់លើការចំណាយសំបក និងក្រិតប្រចាំខែ (S/2 d3)*

បទដ្ឋានអន្តរជាតិនៃការចៀរមុខលើ (S/4 U) សម្រាប់ចង្វាក់ចៀរd3 និងd4៖

- S/4U d3: ចំណាយសំបកក្នុង១ឆ្នាំ18-25cm ដែលល្អបំផុតគឺ 18cm (កម្រាស់សំបកក្នុង១ពន្លាក1,5mm - 2mm)
- S/4Ud4: ចំណាយសំបកក្នុង១ឆ្នាំ15-20cmដែលល្អបំផុតគឺ 15cm(កម្រាស់សំបកក្នុង១ពន្លាក1,8mm - 2,2mm)



*រូបភាពទី៣៖ ការវាស់លើការចំណាយសំបក និងក្រិតប្រចាំខែ (S/4 U d3)*

## ២.២- ជម្រៅចៀរ (Tapping depth)

ជម្រៅចៀរដ៏ល្អបំផុត គឺមានចម្ងាយ ១,៥ម.ម. ពីកំប៊ីយ៉ូម (ធ្វើឲ្យមានចលនាផ្លាស់ប្តូរជាតិស្ករតាមផ្លូវអែម (phloem) បានល្អ ដែលជួយបង្កើនការផលិតទឹកជ័រឡើងវិញ និងចៀសវាងរបួស)។

ប្រសិនបើជម្រៅចៀរមិនគ្រប់គ្រាន់ទេនោះ(ចៀររាក់) ធ្វើឲ្យគេមិនអាចចៀរទៅដល់សរសៃទឹកជ័រថ្មីនៅខាងក្នុងដែលជាទីតាំងផលិតទឹកជ័រច្រើនជាងគេ។ ជាលទ្ធផល បណ្តាលឲ្យបាត់បង់ទិន្នផលពី៥% ទៅ១០% ។



*រូបភាពទី៤៖ការចៀររាក់(ដោយគ្មានរបួសនៅលើផ្ទាំងចៀរគួរតែពិនិត្យជាប្រព័ន្ធទៅលើជម្រៅចៀរ)*

ប្រសិនបើជម្រៅចៀរជ្រៅពេក ធ្វើឲ្យការដឹកជញ្ជូនស្ករតាមរយៈផ្លូវអែម (phloem) ត្រូវបានខូចទ្រង់ទ្រាយ ហើយសក្តានុពលទិន្នផលត្រូវបានកាត់បន្ថយនៅលើផ្ទៃសំបកផ្នែកខាងក្រោម ជាពិសេសទាក់ទងទៅនឹងការឆ្លើយតបរំញោចកម្ម។ វាកាន់តែធ្ងន់ធ្ងរថែមទៀត នៅពេលដែលចៀរប៉ះកំប៊ីយ៉ូម (Cambium) ដែលធ្វើឲ្យរបួស។ មុខរបួសនាំឲ្យមានការកាត់ផ្តាច់ការដឹកជញ្ជូនជាតិស្ករតាមផ្លូវអែម សម្រាប់ផ្គត់ផ្គង់ទៅឲ្យផ្ទៃសំបកផ្នែកខាងក្រោម ដែលនេះមិនអាចអោយយើងវិលត្រឡប់មកកាន់ភាពប្រសើរវិញបានឡើយ។

ប្រសិនបើចៀររាក់ គឺគ្រាន់តែជាមូលហេតុនៃការយកផលទឹកជ័រមិនបានពេញលេញ(under exploitation) តែប៉ុណ្ណោះ និងអាចកែតម្រូវវិញបាន ប៉ុន្តែបើរបួស គឺមិនអាចវិលត្រឡប់មកដូចដើមវិញបានទេ និងនាំឲ្យមានផលអវិជ្ជមានជាច្រើន។



*រូបភាពទី៥៖ ការខូចខាតសំបកដែលមិនអាចកែប្រែបាន ដោយសារតែរបួស (ចៀរដល់សាច់ឈើ)។ ការខូចខាតបែបនេះអាចនាំឲ្យមានការចាប់ផ្តើមនៃស្ងួតផ្ទាំងចៀរ អាស្រ័យដោយសារការបង្អាក់ដឹកជញ្ជូនជាតិស្ករតាមផ្លូវអែម(phloem)*

## ៣- ប្រព័ន្ធចៀរ (Tapping system)

ប្រព័ន្ធចៀរផ្សំឡើងដោយការរួមបញ្ចូលគ្នានៃចង្វាក់ចៀរ ការធ្វើរំញោចកម្មសមស្រប ការគ្រប់គ្រងផ្ទាំងចៀរ ការគ្រប់គ្រងពេលផ្អាកចៀរ និងការប្រើប្រាស់ក្បាំងទឹកភ្លៀង (ឬមិនប្រើប្រាស់)។

### ៣.១- ចង្វាក់ចៀរ (Tapping frequency)

#### ៣.១.១- ការចៀរធម្មតា (Conventional tapping)

ក្រោមលក្ខខណ្ឌបច្ចុប្បន្ននៅប្រទេសកម្ពុជា ចង្វាក់ចៀរដែលបានណែនាំមានតែ២ប្រភេទប៉ុណ្ណោះគឺ d3 និងd4។ កសិករកៅស៊ូគ្រួសារទទួលផលិតផលពីដី

ចម្ការ គិតជាគីឡូក្រាម/ហិកតា ដោយអនុវត្តជាមួយចង្វាក់ចៀរ d3 ដើម្បីទទួលបានទិន្នផលជ័រជាអតិបរមាក្នុងមួយហិកតា។ ចម្ការកៅស៊ូកសិឧស្សាហកម្ម ចូលចិត្តប្រើប្រាស់ចង្វាក់ចៀរ d4 ដើម្បីកាត់បន្ថយថ្លៃដើមពលកម្មនិងហេដ្ឋារចនាសម្ព័ន្ធ (ការស្នាក់នៅ ការដឹកជញ្ជូន...) និងបង្កើនផលិតភាពពលកម្ម ជាពិសេសនៅក្នុងបរិបទដែលកៅស៊ូមានតម្លៃទាប និងកង្វះខាតកម្លាំងពលកម្មក្នុងតំបន់អភិវឌ្ឍន៍ដាំដុះកៅស៊ូថ្មី។ ការប្រើប្រាស់ចង្វាក់ចៀរ d4 ជាទូទៅធ្វើឲ្យទិន្នផលថយចុះក្នុងមួយដើម (គីឡូក្រាម/ដើម) ឬក្នុងមួយហិកតា (គីឡូក្រាម/ហិកតា) ចំនួន៥% បើប្រៀបធៀបទៅនឹងចង្វាក់ចៀរ d3 ប៉ុន្តែកើនផលក្នុងមួយពលកម្មចៀរ (ក្រាម/ពលកម្ម/ដើម ឬគ.ក្រ/ពលកម្ម/ថ្ងៃ) ប្រហែលជា ២០% ។

### ៣.១.២- ការចៀរសម្លាប់ដើម(Intensive tapping)

អំឡុងពេល ៣ ឬ ៤ឆ្នាំចុងក្រោយ មុនកាប់និងដាំដុះកៅស៊ូឡើងវិញ ការចៀរជ័រត្រូវបង្កើនសកម្មភាព ដើម្បីទទួលបានទិន្នផលកៅស៊ូជាអតិបរមាដោយមិនគិតពីនិរន្តរភាព។ ចង្វាក់ចៀរd3 ជាមួយនឹងអាំងតង់ស៊ីតេរំញោចកម្មខ្ពស់គឺជាជម្រើសតែមួយគត់សម្រាប់ការចៀរសម្លាប់ដើម។

ប្រសិនបើការចៀរសម្លាប់ដើមចាប់ផ្តើមរយៈពេល៣ឆ្នាំមុនការដាំដុះឡើងវិញ ការអនុវត្តត្រូវប្រើប្រាស់តាមលំដាប់លំដោយមានដូចខាងក្រោម៖

- ឆ្នាំ n-3: S/2 U d3 ET 5% 15/Y
- ឆ្នាំ n-2: S/2 d3 + S/2 U d3 ET 5% 15/Y
- ឆ្នាំ n-1: S/2 d3 + S/2 U d3 ET 5% 15/Y រហូតដល់ពេលកាប់។ ជាទូទៅនៅឆ្នាំទី៣ នៃការចៀរសម្លាប់ដើមមិនមែនជាឆ្នាំពេញលេញទេ គឺមានរយៈពេលតែ៦ទៅ៨ខែប៉ុណ្ណោះ មុនពេលចាប់ផ្តើមកាប់ដើម។

ប្រសិនបើការចៀរសម្លាប់ដើមចាប់ផ្តើមរយៈពេល៤ឆ្នាំមុនការដាំដុះឡើងវិញ ការអនុវត្តត្រូវបានប្រើប្រាស់តាមលំដាប់លំដោយមានដូចខាងក្រោម៖

- ឆ្នាំ n-4: S/2 U d3 ET 2.5% 12/Y
- ឆ្នាំ n-3: S/2 U d3 ET 5% 15/Y
- ឆ្នាំ n-2: S/2 d3 + S/2 U d3 ET 5% 15/Y
- ឆ្នាំ n-1: S/2 d3 + S/2 U d3 ET 5% 15/Y រហូតដល់ពេលកាប់។ ជាទូទៅនៅឆ្នាំទី៤ នៃការចៀរសម្លាប់ដើមមិនមែនជាឆ្នាំពេញលេញទេ គឺមានរយៈពេលតែ៦ទៅ៨ខែប៉ុណ្ណោះ មុនពេលចាប់ផ្តើមកាប់ដើម។

### ៣.២- លំដាប់លំដោយនៃការគ្រប់គ្រងផ្ទាំងចៀរ (Panel management sequence)

ការគ្រប់គ្រងផ្ទាំងចៀរសម្រាប់ប្រទេសកម្ពុជាត្រូវបានផ្តល់អនុសាសន៍ ឲ្យប្រើចង្វាក់ចៀរd3 និង d4 ដូចមានបង្ហាញក្នុងតួលេខខាងក្រោម។ អនុសាសន៍នេះត្រូវបានធ្វើឡើងចំពោះចម្ការកៅស៊ូគ្រួសារ ឬចម្ការកៅស៊ូកសិឧស្សាហកម្ម ក្នុងគោលបំណងបន្ថយហានិភ័យលើការបាក់ដើមដោយសារខ្យល់និងដើម្បីចៀរជ័រឲ្យបានរយៈពេល២៧ឆ្នាំ (រយៈពេល២៤ឆ្នាំសម្រាប់ចៀរធម្មតា និង៣ឆ្នាំសម្រាប់ចៀរសម្លាប់ដើម)។ ការអនុវត្តចៀរលើសំបកកំណើតមានរយៈពេល២៥ឆ្នាំ ដូចខាងក្រោម ៖

- ឆ្នាំទី១ (បើកមុខចៀរ):
  - កម្ពស់ ១,៣០ m ពីដី S/2 d3. BO-1 (1)
  - កម្ពស់ ១,២០ m ពីដី S/2 d4. BO-1 (1)
- ឆ្នាំទី២: S/2 BO-1 (2)
- ឆ្នាំទី៣: S/2 BO-1 (3)
- ឆ្នាំទី៤: S/2 BO-1 (4)
- ឆ្នាំទី៥: S/2 BO-1 (5)
- ឆ្នាំទី៦: S/2 BO-1 (6)

- ឆ្នាំទី៧: S/2 BO-2 (1)
- ឆ្នាំទី៨: S/2 BO-2 (2)
- ឆ្នាំទី៩: S/2 BO-2 (3)
- ឆ្នាំទី១០: S/2 BO-2 (4)
- ឆ្នាំទី១១: S/4 U HO-1 (1)
- ឆ្នាំទី១២: S/4 U HO-2 (1)
- ឆ្នាំទី១៣: S/2 BO-2 (5)
- ឆ្នាំទី១៤: S/4 U HO-3 (1)
- ឆ្នាំទី១៥: S/4 U HO-4 (1)
- ឆ្នាំទី១៦: S/2 BO-2 (6)
- ឆ្នាំទី១៧: S/4 U HO-1 (2)
- ឆ្នាំទី១៨: S/4 U HO-2 (2)
- ឆ្នាំទី១៩: S/2 BO-2 (7) ឬ S/2 B1-1 ប្រសិនបើសំបកមិនគ្រប់គ្រាន់
- ឆ្នាំទី២០: S/4 U HO-3 (2)
- ឆ្នាំទី២១: S/4 U HO-4 (2)
- ឆ្នាំទី២២: S/2 BO-2 (8) ឬ S/2 B1-1 ប្រសិនបើសំបកមិនគ្រប់គ្រាន់
- ឆ្នាំទី២៣: S/4 U HO-1 (3)
- ឆ្នាំទី២៤: S/4 U HO-2 (3)
- ឆ្នាំទី២៥: S/2 U HO-3/4 (3) ឆ្នាំដំបូងនៃការចៀរសម្លាប់ដើមមុនពេលកាប់
- ឆ្នាំទី២៦: S/2 B1-1 + S/2 U HO-1/2 (4) ឆ្នាំទី២នៃការចៀរសម្លាប់ដើមមុនពេលកាប់
- ឆ្នាំទី២៧: S/2 B1-1 + S/2 U HO-3/4 (4) រយៈពេល៦ខែមុនកាប់

លំដាប់លំដោយនៃការគ្រប់គ្រងផ្ទាំងចៀរត្រូវបានបង្ហាញតាមរូបភាពខាងក្រោម៖




រូបភាពទី៦៖ លំដាប់លំដោយនៃការគ្រប់គ្រងផ្ទាំងចៀរសម្រាប់អនុសាសន៍ចង្វាក់ចៀរ d3 និង d4

ជាចុងក្រោយ បន្ទាប់ពីឆ្នាំទី២៤ គេអាចបន្តចៀរលើសំបកដុះឡើងវិញនៅផ្ទាំងចៀរមុខក្រោម(S/2) ប្រសិនបើដើមកៅស៊ូនៅមានកំរិតខ្ពស់ ឬគ្រប់គ្រាន់លើផ្នែកសេដ្ឋកិច្ចក្នុងការទាញយកទិន្នផលជ័រក្នុងមួយហិកតា។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តរបៀបនេះមិនត្រូវបានគេណែនាំឲ្យប្រើទៀតទេ ព្រោះវាពន្យារពេលដល់ការជ្រើសរើសដាំដុះក្លូនថ្មីនៅចម្ការ។ មួយវដ្តនៃដំណាំកៅស៊ូ គឺរយៈពេល៦ឆ្នាំសម្រាប់ដំណាក់កាលកៅស៊ូមិនទាន់ផ្តល់ផល និងបន្ទាប់មកចំនួន២៧ឆ្នាំសម្រាប់ដំណាក់កាលកៅស៊ូពេញវ័យគឺមានរយៈពេលគ្រប់គ្រាន់ និងសមហេតុផល (សរុបចំនួន៣៣ ឆ្នាំ)។

គ្រប់ការបើកចៀរមុខលើS/4 U ទាំងអស់ ត្រូវតែអនុវត្តនៅកម្ពស់៣ស.ម. ពីលើមុខចៀរមុខក្រោម ដើម្បីរក្សាទុកសំបកកំណើតនេះសម្រាប់ចៀរមុខក្រោមចំនួន១ពន្លាក ឬ២ពន្លាក ក្នុង១ខែ ក្នុងគោលបំណងដើម្បីរំញោចលើសំបកកំណើត និងប្រមូលទឹកជ័រដែលហូរពីការចៀរមុខលើ ប្រសិនបើមាន។ មុំចៀរគ្រប់ប្រព័ន្ធចៀរឡើងលើ (S/4 U ឬ S/2 U) គឺមុំ ៤៥ដឺក្រេ។

### ៣.៣ - ការធ្វើរំញោចកម្ម (ដោយថ្នាំអេតេហ្វូន) (Ethephon stimulation)

#### ៣.៣.១- វិធីសាស្ត្រនៃការធ្វើរំញោចកម្ម (Method of stimulation)

ការធ្វើរំញោចកម្មត្រូវបានណែនាំឲ្យអនុវត្តលើសំបកដុះថ្មីក្បែរមុខចៀរ (Panel application, PA)។ វិធីនេះត្រូវលាបជាបន្ទះដែលមានទទឹង១ស.ម. ពីមុខចៀរសម្រាប់ការចៀរមុខក្រោម ឬទទឹង១ស.ម. ពីមុខចៀរចុះក្រោម សម្រាប់ការចៀរមុខលើ។



*រូបភាពទី៧៖ ការអនុវត្តរំញោចកម្មលើផ្ទាំងចៀរ*




*រូបភាពទី៨៖ ការលាបថ្នាំរំញោចលើការចៀរមុខក្រោម*




*រូបភាពទី៩៖ ការលាបថ្នាំរំញោចការចៀរមុខលើ*

ថ្នាំរំញោចអាចលាបដោយប្រើជក់ដែលមានទទឹងមុខប្រវែង១ស.ម.ឬ ដោយប្រើច្រាសដុសធ្មេញ ដើម្បីកុំឲ្យបរិមាណថ្នាំមានការប្រែប្រួល។

### ៣.៣.២-ប៉ារ៉ាម៉ែត្រនៃការធ្វើរំញោចកម្ម ( **Stimulation parameters**) (បរិមាណថ្នាំប្រើក្នុងមួយដើម កំហាប់ថ្នាំ ចំនួនដងប្រើក្នុងមួយឆ្នាំ ការបែងចែកពេលវេលាលាបសម្រាប់រយ:ពេល១ឆ្នាំ)

អាំងតង់ស៊ីតេរំញោចកម្មគឺអាស្រ័យលើចង្វាក់ចៀរ ទិសដៅចៀរ ឆ្នាំចៀរ និងក្លូន (ស្ថានភាពមេតាបូលីស នៃប្រភេទក្លូននីមួយៗ)។

តារាងខាងក្រោមនេះគឺជាការផ្តល់អនុសាសន៍នៃការធ្វើរំញោចកម្មសម្រាប់ចង្វាក់ចៀរ d3 និង d4 ចំពោះការចៀរមុខក្រោម(S/2) និងចៀរមុខលើ (S/4 U) ចំនួនដងក្នុងមួយឆ្នាំ និងទៅតាមក្លូនសំខាន់ៗ។

- ចំពោះការចៀរមុខក្រោម (S/2) លើសំបកកំណើត កំហាប់ថ្នាំអេតេហ្វូនគឺ ២,៥% ដែលជាការផ្តល់អនុសាសន៍តែមួយគត់ ទោះបីជាក្លូននិងឆ្នាំចៀរ សម្រាប់ចង្វាក់ចៀរ d3 ឬ d4 ខុសគ្នាក៏ដោយ
- ចំពោះការចៀរមុខក្រោម (S/2) លើសំបកដុះថ្មី (នៅពេលចាប់ផ្តើម) កំហាប់ថ្នាំអេតេហ្វូនគឺ ៣,៣% ប៉ុណ្ណោះដែលបានផ្តល់អនុសាសន៍ (ប៉ារ៉ាម៉ែត្រដទៃ

ទៀតនៅដដែលដូចគ្នានឹងសំបកកំណើត) ទោះបីជាក្លូននិងឆ្នាំចៀរ សម្រាប់ចង្វាក់ចៀរ d3 ឬ d4 ខុសគ្នាក៏ដោយ

- ចំពោះការចៀរមុខលើ (S/4 U) កំហាប់ថ្នាំអេតេហ្វូនគឺ ៥% ជាអនុសាសន៍តែមួយគត់ ទោះបីជាក្លូននិងឆ្នាំចៀរ សម្រាប់ចង្វាក់ចៀរ d3 ឬ d4 ខុសគ្នាក៏ដោយ
- ជាធម្មតា ការធ្វើរំញោចកម្មត្រូវបានផ្តល់អនុសាសន៍ឲ្យអនុវត្តចាប់ពីខែមេសា-ឧសភា ដល់ខែធ្នូ ដោយមិនអាស្រ័យលើអាកាសធាតុ ដើម្បីរក្សាការធ្វើសកម្មភាពមេតាបូលីសជាប្រចាំរបស់សរសៃទឹកជ័រ
- បរិមាណមធ្យមល្អបំផុតនៃថ្នាំរំញោចដែលត្រូវប្រើក្នុងមួយដើមក្នុងពេលលាបម្តងសម្រាប់ចៀរមុខក្រោម(S/2) នៅឆ្នាំទី១ មានបរិមាណ០,៧ ក្រាម។ បរិមាណនេះកើនឡើង ០,១ក្រាម រៀងរាល់៤ឆ្នាំម្តង ដើម្បីឲ្យថ្នាំរំញោចលាបលើមុខចៀរមានបរិមាណស្មើគ្នា។ ការបង្កើនបរិមាណថ្នាំនេះគឺសមមាត្រទៅនឹងការកើនឡើងនៃទំហំដើមកៅស៊ូ
- ចំពោះការចៀរមុខលើ(S/4U) បរិមាណមធ្យមដ៏ល្អបំផុតនៃថ្នាំរំញោចដែលត្រូវប្រើក្នុងមួយដើមក្នុងពេលលាបម្តង គឺរក្សាបរិមាណថេរគ្រប់ពេលមានចំនួន០,៨ ក្រាម។

អនុសាសន៍រំញោចកម្មលើក្លូនកៅស៊ូ អាស្រ័យលើស្ថានភាពមេតាបូលីសនៃប្រភេទក្លូននីមួយៗ ដែលផ្តល់អនុសាសន៍ដោយមជ្ឈមណ្ឌលសហប្រតិបត្តិការស្រាវជ្រាវអន្តរជាតិដើម្បីអភិវឌ្ឍន៍កសិកម្ម(CIRAD) ដែលកំណត់លើលក្ខណៈសម្បត្តិសរីរសាស្ត្រចំនួនពីររបស់ប្រព័ន្ធទឹកជ័រនៃក្លូន៖

- មេតាបូលីសទឹកជ័រ (បង្ហាញអំពីថាមពលមេតាបូលីសដែលអាចដំណើរការផលិតទឹកជ័របានឡើងវិញ) បែងចែកជា៥ចំណាត់ថ្នាក់ (មេតាបូលីសខ្ពស់,

ខ្ពស់-មធ្យម, មធ្យម, ទាប-មធ្យម និងទាប) ដែលកំណត់ជាចម្បងនូវកម្រិតទឹកជ័រនៃក្លូននីមួយៗដោយគ្មានប្រើថ្នាំរំញោច

- សមត្ថភាពផ្ទុកជាតិស្ករដើម្បីផលិតទឹកជ័រឬអាងផ្ទុកទឹកជ័រ (បង្ហាញពីការបម្រុងទុកកាបូអ៊ីដ្រាតទឹកជ័រសម្រាប់បង្កើនការចៀរជ័រ) បែងចែកជា៣កម្រិត (ទាប មធ្យម និងខ្ពស់) ដែលកំណត់ជាចម្បងលើការឆ្លើយតបរបស់ក្លូនទៅនឹងរំញោចកម្ម ឬជាទូទៅសម្រាប់បង្កើនការចៀរជ័រ។

ការរួមបញ្ចូលគ្នានៃកត្តាទាំងពីរនេះបង្កើតបានជាតារាងម៉ាទ្រីសតាមប្រភេទក្លូន(៥ជួរឈរ x ៣បន្ទាត់ផ្តេក)ដូចមានបង្ហាញខាងក្រោម។ នៅក្នុងតារាងម៉ាទ្រីសនេះ ការធ្វើរំញោចកម្មទៅលើក្លូន ត្រូវបានថយចុះនៅពេលដែល មេតាបូលីសទឹកជ័រកើនឡើង(ពីឆ្វេងទៅស្តាំនៅក្នុងតារាងម៉ាទ្រីស)។ ការធ្វើរំញោចកម្មលើក្លូនត្រូវបានកើនឡើង នៅពេលដែលការផ្ទុកជាតិស្ករសម្រាប់បង្កើតទឹកជ័រកើនឡើង (ពីលើចុះក្រោម នៅក្នុងតារាងម៉ាទ្រីស)។ តាមរយៈតារាង ម៉ាទ្រីសប្រភេទក្លូនអាំងតង់ស៊ីតេរំញោចកម្មចំនួន៥ ត្រូវបានផ្តល់អនុសាសន៍សម្រាប់ប្រើថ្នាំរំញោចលើក្លូននីមួយៗ។ អាំងតង់ស៊ីតេរំញោចកម្មទាំង៥នេះ បង្ហាញលើបន្ទាត់អង្កត់ទ្រូង ពីទិសពាយព្យ ទៅអាគ្នេយ៍ (បន្ទាត់ពណ៌ក្រហម)នៃតារាងម៉ាទ្រីស និងមានក្លូនចំនួន១៣ថ្នាក់៖

- **ការធ្វើរំញោចកម្មតិចបំផុត**
  - ថ្នាក់ក្លូនទី១២ (C12) ៖ មេតាបូលីសខ្ពស់ និងកម្រិតផ្ទុកជាតិស្ករមធ្យម (ឧ. PB 235, PB 260)
  - ថ្នាក់ក្លូនទី៩ (C9) ៖ មេតាបូលីសខ្ពស់-មធ្យម និងកម្រិតផ្ទុកជាតិស្ករទាប (គ្មានឧទាហរណ៍)
- **ការធ្វើរំញោចកម្មតិច**
  - ថ្នាក់ក្លូនទី១៣ (C13) ៖ មេតាបូលីសខ្ពស់ និងកម្រិតផ្ទុកជាតិស្ករខ្ពស់ (ឧ. IRCA 230, PB 255)

- ថ្នាក់ក្លូនទី១០ (C10) ៖ មេតាបូលីសខ្ពស់-មធ្យម និងកម្រិតផ្ទុកជាតិស្ករមធ្យម (ឧ. RRIM 600)
- ថ្នាក់ក្លូនទី៦ (C6) ៖ មេតាបូលីសមធ្យម និងកម្រិតផ្ទុកជាតិស្ករទាប (គ្មានឧទាហរណ៍)

- **ការធ្វើរំញោចកម្មមធ្យម**
